# ដើមបណ្តឹងរដ្ឋប្បវេណីចង់ឱ្យឃើញពីគម្រោងជួសជុលសំណងក្នុងសំណុំរឿង ០០២/០១

អែន ហេនខែល ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រែសម្រួលដោយ វ៉ាន់ថាន់ ពៅដារ៉ា

១៥ កុម្ភៈ ២០១៣

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចង់ឲ្យឃើញពីគម្រោងជួសជុលសំណងជាច្រើន រួមទាំងស្ថានភាពដែលខ្លួនអាចមានថវិកា ដែលខ្លួនមានបំណងចង់ស្នើសុំបញ្ចូលក្នុងសំណុំរឿង០០២/០១ "ដែលទំនងជាអាចសម្រេចបានច្រើន" ។[១] មានគម្រោងចំនួន៧កំពុងត្រូវបានធ្វើឡើង ដូចជា ការទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជាទៅលើទិវាថ្មីស្តីពីការចងចាំជនរងគ្រោះខ្មែរក្រហម ការកសាងស្តូបរំឭកវិញ្ញាណក្ខន្ធជាសាធារណៈពី៣ទៅ៦កន្លែង ដែលជាការទទួលស្គាល់ការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ជាពិសេស គោលនយោបាយផ្លាស់ទីលំនៅដោយបង្ខំក្នុងសំណុំរឿង០០២/០១ ការផ្តល់ថវិកាសម្រាប់សេវាសុខភាពផ្លូវចិត្ត ដូចជាការផ្តល់ប្រឹក្សាផ្នែកសុខភាពផ្លូវចិត្តដល់អ្នកមកផ្តល់សក្ខីកម្ម និងក្រុមជួយខ្លួនឯងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ ការតាំងពិព័រណ៍ចល័តជាមួយខ្សែភាពយន្តខ្លីៗ និងសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលរៀបរាប់ពីការឈឺចាប់ ដោយរួមទាំងការរៀបរាប់អំពីការជម្លៀសដោយបង្ខំ កន្លែងតាំងពិព័រណ៍ឯកសារ រូបភាពសោតទស្សន៍អំពីសក្ខីកម្ម និងការដាក់តាំងបែបសិល្បៈអចិន្ត្រៃយ៍ ដើម្បីថែរក្សាសាច់រឿងផ្សេងៗដែលទាក់ទិននឹងការជម្លៀសដោយបង្ខំក្នុងចំណោមការឈឺចាប់នានា និងសៀវភៅដែលពន្យល់អំពីដំណើរការក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងបទឧក្រិដ្ឋកម្មដែលគ្របដណ្តប់នៅក្នុងសំណុំរឿង ០០២ ។[២] យោងតាមសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ៖

---

[១] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ៖ ការបង្ហាញលទ្ធផលគម្រោងអាទិភាពសម្រាប់ការអនុវត្តន៍ ជាការជួសជុលសំណងខូចខាត (វិធានផ្ទៃក្នុង ៨០ ស្ទួន៤) (ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២) ។

[២] ការបង្ហាញលទ្ធផលបង្ហាញរបស់សហមេធាវីនាំមុខដាក់ជូនអង្គជំនុំជម្រះលើគម្រោងអាទិភាព សម្រាប់ការអនុវត្តន៍ជាការជួសជុលសំណងខូចខាត (វិធានផ្ទៃក្នុង ៨០ ស្ទួន៤) ជាមួយឧបសម្ព័ន្ធសម្ងាត់ (ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣) ។ (អំណោះតទៅគឺហៅ ការបង្ហាញលទ្ធផលជូនអង្គជំនុំជម្រះ) ។

> គម្រោងអធិភាពចំនួនទាំង៧នេះគឺស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការគិតគូរដោយសហការជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ និងអង្គការ និងស្ថាប័នជាដៃគូផ្សេងៗជាច្រើនទៀត ។ អង្គការ និងសាប័នជាដៃគូដែលបានបញ្ជាក់ច្បាស់ទាំងអស់ បានសំដែងចេតនារបស់ខ្លួនទទួលខុសត្រូវលើការអនុវត្តគម្រោងទាំងនោះ ហើយចង់ចុះកិច្ចព្រមព្រៀងផ្តល់ថវិកាផ្ទាល់ជាមួយម្ចាស់ជំនួយលើគម្រោង និង/ឬជាមួយអង្គភាពគាំពារជនរងគ្រោះ ។[៣]

អនុលោមតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំមានអំណាចផ្តល់ជូនសំណងខូចខាតជាបុគ្គលទេគឺមានតែសំណងដែលមាន«លក្ខណៈសមូហភាពនិងផ្លូវចិត្ត»[៤] ប៉ុណ្ណោះ ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់សម្រេចថា ៖

> អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំមានសមត្ថកិច្ចផ្តល់ជូនសំណងលុយកាក់ជាបុគ្គលដល់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។ ការផ្តើមចេញពីច្បាប់ជាតិបែបនេះត្រូវបានចាត់ទុកថាចាំបាច់ក្នុងការពិនិត្យលើចំនួនដើមបណ្តឹងរដ្ឋប្បវេណីច្រើនដែលរំពឹងថាទាមទារនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងភាពលំបាកដែលមិនអាចជៀសផុតពីការវាយតម្លៃលើទំហំនៃការបាត់បង់ឲ្យបានពេញលេញ ដែលប៉ះពាល់ដោយជនរងគ្រោះនូវកម្រិតខុសៗគ្នា ។ ហេតុដូច្នេះ សំណងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំដៅដល់ភាពជានិមិត្តរូបសំខាន់ ជាជាងសំណងលុយកាក់ ។[៥]

---

[៣] ស្តូន វាក្យខណ្ឌ ៤ ។

[៤] វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធាន ២៣ ស្ទួន១ ។ វិធាននេះកំណត់«លក្ខណៈសមូហភាព និងផ្លូវចិត្ត»ថាជាវិធានការដែល(ក)ទទួលស្គាល់ការឈឺចាប់ដែលរងគ្រោះដោយដើមបណ្តឹងរដ្ឋប្បវេណី ដែលបណ្តាលមកពីការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលជនជាប់ត្រូវបានកាត់ឲ្យជាប់ទោស និង(ខ)ផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលដោះស្រាយការឈឺចាប់នេះ ។ ស្ទួន ។

[៥] សាលក្រមឌុចនៅអង្គជំនុំជម្រះ, វាក្យខណ្ឌ៦៦១, កំណត់សម្គាល់១១៤៤ (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) ។ សាលក្រមនេះត្រូវបានសម្រេចផ្ទុយដោយអង្គជំនុំជម្រះតុលាការកំពូល ។ សាលដីកាលើបណ្តឹងសារទុក្ខឌុច, វាក្យខណ្ឌ៦៤៤ (ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២) ។

នៅក្នុងសំណុំរឿង ០០១ ក្រុមដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំការជួសជុលសំណងខូចខាត "ក្នុងកម្រិតអប្បរិមា" ដូចជា ការចងក្រង និងចែកចាយជូនសេចក្ដីថ្លែងការណ៍សុំអភ័យទោសរបស់ប្រធានមន្ទីរសន្តិសុខស-២១ កាំង ហ្កេកអ៊ាវ (ហៅ ឌុច) ជាមួយនឹងយោបល់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ការទទួលបានការថែទាំវេជ្ជសាស្ត្រសម្រាប់អ្នកជំងឺ ការផ្ដល់ថវិកាដល់កម្មវិធីអប់រំអំពីរបបខ្មែរក្រហម និងស-២១ ការសាងស្តូបរំឭកវិញ្ញាណក្ខន្ធ និងវត្តអារាម និងការបញ្ចូលឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម ។[៦]

អនុលោមតាមវិធានផ្ទៃក្នុងជាធរមាននៅក្នុងអំឡុងពេលនោះ ការផ្ដល់នូវសំណងគឺ "សំដៅប្រឆាំងដោយផ្ទាល់ និងលើជនជាប់ចោទតែម្នាក់ឯង"[៧] ហើយឌុចត្រូវបានកំណត់ថា ជាជនទុគ៌ត ។ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ខ្លួនពុំមានសមត្ថកិច្ចលើជនកម្ពុជា ឬអាជ្ញាធរណាមួយ ដែលមិនអាចចេញបញ្ជាដែលមិនអាចមានលទ្ធភាពក្នុងការអនុវត្ត ដោយសារតែកង្វះភាពជាក់លាក់ ហើយយ៉ាងច្រើនអាចត្រឹមតែ "លើកទឹកចិត្ត" គួរអង្គខាងក្រៅក្នុងការផ្ដល់ជូនជនរងគ្រោះនូវការគាំទ្រផ្នែកហិរញ្ញវត្ថុតែប៉ុណ្ណោះ ។[៨] បើទោះជាមានការទទួលស្គាល់នូវគោលការណ៍អន្តរជាតិ ដែលដាក់កាតពកិច្ចលើរដ្ឋឲ្យដោះស្រាយជូនជនរងគ្រោះពីការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្សក៏ដោយ អង្គជំនុំជម្រះសាលាដំបូង បានថ្លែងថា "ខ្លួនត្រូវបានកម្រិតនៅក្នុងសមត្ថកិច្ចឆ្លើយតបនឹងសំណើនៅចំពោះមុខខ្លួន និងប្រភេទនៃការធ្វើសំណងដែលបានអនុញ្ញាតតាមវិធានផ្ទៃក្នុង ។ការកម្រិតបែបនេះពុំអាចនឹងជៀសវាងបានតាមរយៈយុត្តិសាស្ត្រទេ ក៏ប៉ុន្តែត្រូវឲ្យមានវិសោធនកម្មវិធានផ្ទៃក្នុងវិញ" ។ អាស្រ័យហេតុនេះ ខ្លួន ផ្ដល់តាមសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលសុំឲ្យបញ្ចូលឈ្មោះដេមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្ទាល់នៅក្នុងសាលក្រមចុងក្រោយ ព្រមទាំងការរៀបចំ និងបោះពុម្ពរាល់សេចក្ដីថ្លែងការណ៍សុំអភ័យទោសដែលធ្វើឡើងដោយ ឌុច នៅក្នុងអំឡុងពេលសវនាការតែប៉ុណ្ណោះ ។[៩]

---

[៦] សូមមើល ការស្នើសុំរួមគ្នាលើសំណងរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី, សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/TC, វាក្យខណ្ឌ១២-៣០ (ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩) ។

[៧] វិធានផ្ទៃក្នុង អ.វ.ត.ក (ច្បាប់ដើម), វិធាន ២៣(១១) ។

[៨] សូមមើល សាលក្រមឌុចនៅអង្គជំនុំជម្រះ, វាក្យខណ្ឌ៦៦៣-៦៥ ។ សាលក្រមនេះត្រូវបានសម្រេចផ្ទុយដោយអង្គជំនុំជម្រះតុលាការកំពូល ។ សាលដីកាលើបណ្ដឹងសារទុក្ខឌុច, វាក្យខណ្ឌ៦៥៤ ។

[៩] សាលក្រមឌុចនៅអង្គជំនុំជម្រះ, វាក្យខណ្ឌ៦៦២, ៦៦៤-៧៥ ។ សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការបញ្ចូលយោបល់ជាមួយថ្លែងការណ៍សុំអភ័យទោសដែលមិនត្រូវបានទទួលយក ។

នៅក្នុងការប្រមើលមើលលើសំណុំរឿង ០០២ ចៅក្រមបានធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង ដើម្បីពង្រីកអំណាចរបស់ខ្លួនក្នុងការផ្តល់សំណង ។ វិធាន ២៣ (៣)ថ្មី ផ្តល់ជូនចៅក្រមនូវអំណាចទាំងការចេញបញ្ជាថា តម្លៃនៃការផ្តល់សំណងគឺស្ថិតនៅលើជនត្រូវទទួលទោស ឬ«ទទួលស្គាល់ថា គម្រោងជាក់លាក់ ផ្តល់សំណងយ៉ាងសមស្របតាមការស្វែងរករបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីហើយគម្រោងនោះអាចយកទៅអនុវត្តបាន ។ គម្រោងបែបនេះ ត្រូវតែរៀបចំឬចង្អុលបង្ហាញដោយមានការសហការជាមួយអង្គភាពគាំពារជនរងគ្រោះ និងត្រូវធានាថវិកាផ្នែកខាងក្រៅឲ្យបានគ្រប់គ្រាន់» ។ វិសោធនកម្មវិធាននេះបង្កើតឱកាសសម្រាប់ការជួសជុលសំណងឲ្យមានលក្ខណៈទូលំទូលាយ ។ ទោះបីជាយ៉ាងណាក្តី មកដល់ពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូង មិនបានធ្លាប់ផ្តល់នូវក្របខណ្ឌជាក់លាក់ក្នុងការចង្អុលបង្ហាញពីការអនុវត្តន៍របស់ខ្លួនឡើយ ហើយការអនុវត្តន៍ជាក់ស្តែងជាច្រើននៅមានលក្ខណៈមិនច្បាស់លាស់ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចែករំលែកការទទួលខុសត្រូវដែលមានលក្ខណៈត្រួតគ្នា ជាមួយអង្គភាពគាំពារជនរងគ្រោះ ក្នុងការបង្កើតគម្រោងសំណង ដោយធ្វើឲ្យដែនសមត្ថកិច្ច និងការទទួលខុសត្រូវចុងក្រោយ ស្ថិតក្នុងភាពមិនច្បាស់លាស់ នៅត្រង់ថា «អង្គភាពគាំពារជនរងគ្រោះ ដោយមានកិច្ចសហការជាមួយសហមេធាវីនាំមុខ ត្រូវខិតខំប្រឹងប្រែង ចង្អុលបង្ហាញ រៀបចំ និងក្រោយមកអនុវត្តគម្រោង»[10] មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្វះស្វែង និងពាំនាំទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងគម្រោងណាមួយដែលមានអត្ថន័យ រួចហើយរៀបចំជាសំណើចុងក្រោយដាក់ជូនអង្គជំនុំជម្រះសាលាដំបូង[11] ក៏ប៉ុន្តែ តួនាទីចម្បងរបស់ខ្លួនគឺការធ្វើជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ ពុំមែនគ្រប់គ្រងលើគម្រោងនោះទេ ។ មេធាវីដើមបណ្តឹងរដប្បវេណីសង្កត់ធ្ងន់ថា ខ្លួនអាចគាំទ្រ និងជួយសម្រួលដំណើរការស្វែងរកថវិកាជាមួយអង្គភាពគាំពារជនរងគ្រោះ បើទោះជាខ្លួន «ពុំមានជំនាញនិងអណត្តិក្នុងការទទួលខុសត្រូវដោយផ្ទាល់ក៏ដោយ»[12] អង្គភាពគាំពារជនរងគ្រោះគឺទទួល

[10] វិធានផ្ទៃក្នុង, វិធាន ១២ស្ទួន២ ។

[11] សូមមើល ស្ទួន, វិធាន ៨០ស្ទួន៤ ។

[12] ការចង្អុលបង្ហាញជូនអង្គជំនុំជម្រះ, កំណត់សម្គាល់លេខ២ខាងដើម, វាក្យខណ្ឌ៣០ ។ ការិយាល័យទាំងពីរត្រូវបានរារាំងដោយកង្វះខាតនូវភាពជំនាញ ។ ដូចដែលបានកត់សម្គាល់កន្លងមកដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ភារកិច្ចរៀបចំគម្រោងសំណងគឺធម្មតាធ្វើឡើងដោយ«ស្ថាប័នជំនាញដែលធ្វើឡើងបានដោយមានបុគ្គលិកច្រើន ថវិកា ពេលវេលា និងបទពិសោធន៍» ដែលពុំអាចរកបានដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឬដោយអង្គភាពគាំពារជនរងគ្រោះ ។ ការធ្វើឲ្យជាក់លាក់បឋមលើខ្លឹមសារនៃការផ្តល់សំណងដែលសហមេធាវីនាំមុខ

ខុសត្រូវលើការអភិវឌ្ឍន៍គម្រោង ហើយត្រូវបានរំពឹងថា «រៀបចំផ្តល់សំណងដែលចន្លលបង្ហាញដោយសហមេធាវីនាំមុខ ព្រមទាំងធានានូវថវិការបស់ខ្លួន និងភាពរួចរាល់សម្រាប់ការអនុវត្តន៍នៅ ដំណាក់កាលសាលក្រមចុងក្រោយ» ។[១៣]

យោងតាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បច្ចុប្បន្ននេះ «អត្តសញ្ញាណ និងគំរូនៃគម្រោងនេះ ស្ថិតក្នុងដំណាក់កាលលូតលាស់ទៅមុខ ប៉ុន្តែការធានាផ្នែកហិរញ្ញវត្ថុ មិនទាន់អាចរកបាននៅឡើយទេ ឬប្រសិនបើអាចរកបានវានៅមិនទាន់ច្បាស់នៅឡើយទេ» ។[១៤] បើទោះជាអង្គជំនុំជម្រះបាននិយាយថា វិធានសងសំណងថ្មី«សន្មត់ជាមុនពីការបង្កើតសំណង(តាមន័យបច្ចេកទេស តាមរយៈការចាត់ចែងកម្មវិធី) ស្របគ្នាជាមួយនឹងការកាត់សេចក្តីនេះ» ។[១៥] វានៅមិនទាន់ច្បាស់នៅឡើយ ថាតើកម្មវិធីនេះត្រូវបង្កើតឡើងនិងមានមូលនិធិពេញលេញមុនពេលទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើឲ្យ ការអនុម័តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈនិមិត្តរូបសុទ្ធសាធ ឬបើសិនជា មានលក្ខណៈគ្រប់គ្រាន់ដែលថាផែនការជាក់ស្តែង ឬការសន្យាផ្តល់មូលនិធិ (ប្រហែលអាស្រ័យលើការទទួលស្គាល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) មានអាទិភាព ។

អង្គជំនុំជម្រះបានផ្តល់ការសង្កេតពីមុនៗអំពីភាពសមស្របចំពោះប្រភេទគម្រោង ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកំពុងផ្តល់អទិភាពដោយមានក្របខណ្ឌសំណងថ្មីរបស់ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាការគួរឲ្យកត់សម្គាល់ អង្គជំនុំជម្រះបង្ហាញថា វិធានការដែលតម្រូវឲ្យមានការអនុម័តពីរដ្ឋាភិបាលកម្ពុជា អាចហួសពីវិសាលភាពនៃអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លើសពីនេះទៀត អង្គជំនុំជម្រះបាននិយាយថា ការស្នើសុំឲ្យកសាងចេតិយ ទីតាំងបូជនីយដ្ឋាន កម្មវិធីអប់រំ និងកិច្ចគាំពារខាងចិត្តសាស្ត្រ តម្រូវឲ្យមានភាពជាក់លាក់គ្រប់គ្រាន់ ។ ឧទាហរណ៍ យោងតាម

---

តំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងចង់ស្វែងរក, សវនាការថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១, វាក្យខណ្ឌ ៤០ (ថ្ងៃទី២ ខែមិនា ឆ្នាំ២០១២) (អំណោះតទៅហៅថា ការធ្វើឲ្យជាក់លាក់បឋមរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី) ។

[១៣] អនុស្សរណៈរបស់អង្គជំនុំជម្រះ : ការធ្វើឲ្យជាក់លាក់បឋមលើខ្លឹមសារនៃការផ្តល់សំណង ដែលស្វែងរកដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធានផ្ទៃក្នុង ២៣ស្ទួន៣ (ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១) (អំណោះតទៅហៅថា ការធ្វើឲ្យជាក់លាក់បឋមរបស់អង្គជំនុំជម្រះ) ។

[១៤] ការចន្លលបង្ហាញជូនអង្គជំនុំជម្រះ, កំណត់សម្គាល់លេខ២ខាងដើម, វាក្យខណ្ឌ៣៦ ។

[១៥] ការធ្វើឲ្យជាក់លាក់បឋមរបស់អង្គជំនុំជម្រះ, កំណត់សម្គាល់លេខ១៣, ទំព័រ២ ។

សាលក្រមទៅលើឌុច អង្គជំនុំជម្រះបានបង្ហាញថា ព័ត៌មានជាក់ស្តែងអំពីទីតាំង ការចំណាយ និងការព្រមព្រៀងពីម្ចាស់ទីតាំងបូជនីយដ្ឋានតាមការស្នើសុំ និងសេចក្តីត្រូវការចំពោះការអនុញ្ញាតផ្នែករដ្ឋបាល មានដូចជាការអនុញ្ញាតចំពោះការកសាង ត្រូវតែបានផ្តល់ «ដើម្បីធានាថាផ្នែកផ្សេងគ្នាប្រកបដោយភាពកម្រិតចំពោះវិធានការទាំងនេះអាចសម្រេចបានយ៉ាងមានអត្ថន័យ ដែលស្ថិតក្នុងក្របខណ្ឌពេលវេលាដែលអាចអនុវត្តបាន» ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះ មិនពន្យល់អំពីកម្រិតនៃភាពជាក់លាក់ឲ្យបានគ្រប់គ្រាន់ ប៉ុន្តែផ្ទុយទៅវិញ បានកំណត់នូវវិធានការដែលស្រដៀងគ្នាទៅនឹងសំណងនៅក្នុងសំណុំរឿង ០០១ ដូចជាការផ្សព្វផ្សាយសាលក្រមនិងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ថាជា «វិធានការដ៏សមស្រប និងអាចសម្រេចបាននៅក្នុងបរិបទរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។[១៦] ប៉ុន្តែការសងសំណងនេះមានរួចស្រាច់ទៅហើយ មុនពេលការអនុម័តច្បាប់ថ្មី ហើយសំណងនោះ ត្រូវបានចាត់ទុកថា «គ្មានប្រសិទ្ធភាព» ពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។[១៧]

នៅទីបញ្ចប់ ភាពជាប់ពាក់ព័ន្ធនៃការបំបែកសំណុំរឿង០០២ទៅជាការកាត់សេចក្តីតូចៗមួយឬពីរស្តីពីសិទ្ធរបស់បុគ្គលម្នាក់ៗនៃដើមបណ្តឹងរដ្ឋប្បវេណី០០២ ចំពោះការសងសំណងនៅតែមិនអាចដោះស្រាយ ។ ប្រធានបទនេះ នឹងត្រូវបានដោះស្រាយនៅក្នុងបទអត្ថាធិប្បាយលើកក្រោយទៀត ។

**– ចប់ –**

---

[១៦] ស្មន. ទំព័រ៣ ។

[១៧] ការធ្វើឲ្យជាក់លាក់បឋមរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី, កំណត់សម្គាល់លេខ១២ខាងដើម, វាក្យខណ្ឌ៥២ ។